# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# កិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី ១៤
# ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា

យើង រដ្ឋមន្ត្រីសុខាភិបាលប្រទេសសមាជិកអាស៊ានអាស៊ានតំណាងឱ្យ ប្រទេសប្រុយណេដារូសាលឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណៈរដ្ឋហ្វីលីពីន សាធារណៈរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម បានចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី១៤ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៩ នៅខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា។

យើងរំលឹកពីចក្ខុវិស័យរបស់ថ្នាក់ដឹកនាំនៃសហគមន៍អាស៊ាន ដែលបានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងគូឡាឡាំពួ ឆ្នាំ២០១៥ ស្តីពីការបង្កើតសហគមន៍អាស៊ាន និងការយល់ព្រមរួមគ្នានៃ "អាស៊ាន ២០២៥៖ ការឆ្ពោះទៅមុខរួមគ្នា " ដែលមាននៅក្នុងសហគមន៍អាស៊ានផែនការសហគមន៍វប្បធម៌សង្គមអាស៊ាន ២០២៥ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ នៅខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

យើងអះអាងសារជាថ្មី ពីការប្តេជ្ញាចិត្តឆ្ពោះទៅលើ "របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" ដូចបានព្រមព្រៀងគ្នាដោយថ្នាក់ដឹកនាំ នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៧០ នៅឆ្នាំ២០១៥ ដែលរួមមានគោលដៅសុខភាពដ៏សំខាន់ ដើម្បី "ធានាឱ្យបាននូវជីវិតប្រកបដោយសុខភាព និងលើកកម្ពស់សុខុមាលភាពសម្រាប់មនុស្សគ្រប់វ័យ" ។

យើងទទួលស្គាល់ថាការប្តេជ្ញាចិត្តឆ្ពោះទៅគោលដៅ "ទាំងអស់គ្នាឆ្ពោះទៅរកអាស៊ានប្រកបដោយសុខភាព" នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី១៣ ដែលបានប្រព្រឹត្តនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៧ នៅទីក្រុង បេនដាសារី បេហ្គាវ៉ាន់ (Bandar Sari Begawan) នៃប្រទេសប្រ៊ុយណេដារូសាឡឹម ដែលបានប្តេជ្ញាកសាងផែនការ ពហុវិស័យ និងពហុភាគីពាក់ព័ន្ធនឹងការអនុវត្តសេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានលើ (១) ភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិចៈ ការប្រយុទ្ធប្រឆាំងនឹង ភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិចតាមរយៈអភិក្រមសុខភាពតែមួយ (២) ការបញ្ចប់រាល់ទម្រង់នៃកង្វះអាហាររូបត្ថម្ភ និង (៣) ការគ្រប់គ្រងសុខភាពបណ្តាលពីគ្រោះមហន្តរាយ និងប្តេជ្ញាអនុវត្ត និងតាមដានពិនិត្យមើលកម្មវិធីការងារនៃក្រុមការងារសខាភិបាលអាស៊ានទាំង៤ដែលបានឯកភាព និងអាទិភាពសុខភាពទាំង២០ ស្តីពីការលើកកម្ពស់របៀបរស់នៅប្រកបដោយសុខភាព ការឆ្លើយតបទៅនឹងហានិភ័យទាំងអស់ និងការគំរាមកំហែងដែលកំពុងកើតឡើងការពង្រឹងប្រព័ន្ធសុខាភិបាលនិងការទទួលបានការថែទាំ និងការធានាសុវត្ថិភាពចំណីអាហារ។

យើងរួមគ្នាតាមរយៈបេសកកម្ម ដើម្បីសម្រេចបានគោលដៅនៃរបៀបវារៈអភិវឌ្ឍន៍សុខភាពអាស៊ានក្រោយឆ្នាំ២០១៥ និងដើម្បី "ពន្លឿនសុខភាពសម្រាប់ទាំងអស់គ្នាក្នុងអាស៊ាន" រួមទាំងការប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងអន់គុណភាព ការធានានូវហិរញ្ញវត្ថុសុខាភិបាលប្រកបដោយចីរភាព និងការពង្រឹងសមត្ថភាពដើម្បីអនុវត្តច្បាប់សុខភាពអន្តរជាតិ (IHR) តាមរយៈយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិកដើម្បីបង្ការ និងទប់ស្កាត់ជំងឺឆ្លងថ្មីៗនិងគ្រោះអាសន្នសុខភាពសាធារណៈ (APSED III) និងជំរុញនវានុវត្តន៍សម្រាប់លើកកម្ពស់គុណភាពសេវា។ កិច្ចប្រជុំនេះបានពិភាក្សា និងបានផ្លាស់ប្តូរទស្សនៈស្តីពីការរៀបចំនិងការឆ្លើយតបទៅនឹងបញ្ហាប្រឈមសុខភាពនានា និងរបៀបវារៈសម្រាប់ការអភិវឌ្ឍសុខភាពក្នុងពេលអនាគត ព្រមទាំងអាទិភាពផ្សេងទៀត ហើយបានឯកភាពដូចខាងក្រោម៖

1. យើងឯកភាពប្រើប្រាស់សមិទ្ធិផលពីការអនុវត្តរបៀបវារៈអភិវឌ្ឍវិស័យសុខាភិបាលអាស៊ានក្រោយឆ្នាំ២០១៥ និងនិរន្តរភាពឆ្ពោះទៅរកការអភិវឌ្ឍកម្មវិធីការងារថ្មីៗ និងគំនិតផ្តួចផ្តើមគម្រោងសម្រាប់ឆ្នាំ ២០២១-២០២៥ ដោយផ្អែកលើការអនុវត្តកម្មវិធីការងារសម្រាប់ឆ្នាំ ២០១៦-២០២០ និងវិធីសាស្ត្រសង្គមទាំងមូល និងរដ្ឋាភិបាលទាំងមូល។
2. យើងប្តេជ្ញាលើកកម្ពស់សុខភាព និងរក្សាភាពសកម្មក្នុងវ័យចំណាស់ តាមរយៈបរិយាកាសគាំទ្រ និងអំណោយផល ដែលសម្របសម្រួលកិច្ចសហប្រតិបត្តិការពហុវិស័យយ៉ាងរឹងមាំនិងមានប្រសិទ្ធភាព តាមរយៈគំនិតផ្តួចផ្តើមរួមគ្នាថ្នាក់ជាតិ និងថ្នាក់តំបន់។ យើងគាំទ្រការបង្កើតមជ្ឈមណ្ឌលអាស៊ានសម្រាប់សុខុមាលភាពមនុស្សចាស់ និងការច្នៃប្រឌិតថ្មី (ACAI) ដែលនឹងបង្កើតចំណេះដឹង និងការច្នៃប្រឌិត គាំទ្រដល់គោលនយោបាយសុខុមាលភាពមនុស្សចាស់ និងការអនុវត្តរបស់ពួកគាត់ និងពង្រឹងសមត្ថភាពនិងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងប្រទេសសមាជិកអាស៊ាន អង្គភាពអន្តរជាតិ និងដៃគូដទៃទៀតលើបញ្ហាដែលទាក់ទងទៅនឹងសុខុមាលភាពមនុស្សចាស់។
3. យើងបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការខិតខំប្រឹងប្រែងបង្កើនវិធានការដើម្បីការពារ និងត្រួតពិនិត្យជំងឺមិនឆ្លង តាមរយៈការលើកកម្ពស់សមត្ថភាពសហគមន៍ និងប្រជាជន ពីរបៀបរស់នៅប្រកបដោយសុខភាព ការកៀងគរមូលនិធិប្រកបដោយចីរភាពសម្រាប់ប្រយុទ្ធនឹងជំងឺមិនឆ្លង (NCD) និងពង្រឹងការចូលរួមពហុវិស័យ ព្រមទាំងភាគីពាក់ព័ន្ធក្នុងការអនុវត្តតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក "best buy" និងបទអន្តរាគមន៍ផ្សេងទៀតស្របតាមបរិបទប្រទេស ដោយស្វែងរកដោះស្រាយកត្តាកំណត់ពាណិជ្ជកម្មនិងសង្គមរបស់ជំងឺមិនឆ្លង (NCD) និងក្របខណ្ឌយុទ្ធសាស្ត្រអាស៊ាន និងផែនការសកម្មភាពសម្រាប់អាហារូបត្ថម្ភ ឆ្នាំ ២០១៨-២០៣០ ដើម្បីលើកកម្ពស់អាហារូបត្ថម្ភនិងរបបអាហារមានសុខភាពល្អ លើកកម្ពស់សកម្មភាពសុខភាពផ្លូវកាយនិងផ្លូវចិត្ត កម្មវិធីធ្វើរោគវិនិច្ឆ័យឱ្យបានឆាប់ និងព្យាបាលទាន់ពេលវេលា និងការបង្ការរបួស។
4. យើងឯកភាពគ្នាក្នុងការខិតខំប្រឹងប្រែងបន្តទៀត ចំពោះកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនិងការអនុវត្តសកម្មភាពបន្តសម្រាប់ការត្រៀមជាមុន ក្នុងការបង្ការ ការស្រាវជ្រាវ និងការឆ្លើយតបចំពោះជំងឺថ្មី ជំងឺរាតត្បាតថ្មីៗផ្សេងទៀត និងជំងឺឆ្លង និងគ្រោះអាសន្នសុខភាពសាធារណៈ ឬផលប៉ះពាល់សុខភាពនៃគ្រោះមហន្តរាយនានា និងការគំរាមកំហែងសន្តិសុខសុខភាព។
5. យើងគាំទ្រលើ "**អាស៊ានមួយ ការឆ្លើយតបមួយ**" ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌តាមរយៈការធ្វើប្រតិបត្តិការលើផែនការសកម្មភាព ដើម្បីអនុវត្តសេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីការគ្រប់គ្រងសុខភាពបណ្តាលពីគ្រោះមហន្តរាយ។ យើងក៏ថ្លៃអំណរគុណនូវភាពជាដៃគូដែលកំពុងបន្តលើការពង្រឹងសមត្ថភាពតំបន់អាស៊ានស្តីពីការគ្រប់គ្រងសុខភាពគ្រោះមហន្តរាយ និងកម្មវិធីស្តីពីការកាត់បន្ថយការគំរាមកំហែងផ្នែកជីវសាស្ត្រ។

៨

៦. យើងបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តចំពោះសេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិក (AMR) ហើយនឹងរង់ចាំការការអនុម័តលើក្របខ័ណ្ឌយុទ្ធសាស្ត្រអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិក (AMR) តាមរយៈវិធីសាស្ត្រសុខភាពតែមួយ (២០១៩-២០៣០) ដើម្បីចូលរួមក្នុងការសម្រេចបាននូវសន្តិសុខ សុខភាពថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលពាក់ព័ន្ធ សម្រាប់មនុស្ស សត្វ និងកសិកម្ម សុខភាពបរិស្ថាន និងសុវត្ថិភាពចំណីអាហារ។

៧. យើងសូមគូសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយនិងអន់គុណភាព។

៨. យើងគាំទ្រការពិនិត្យចុងក្រោយលើផែនការសកម្មភាពអាស៊ាន ដែលបានបង្កើតឡើងជាមួយអង្គការសុខភាពពិភពលោក (WHO) ក្នុងការប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងអន់គុណភាព ដោយពង្រឹងយន្តការច្បាប់ជាតិ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការលើការអនុវត្តប្រកបដោយចីរភាពលើការបង្ការ ការស្រាវជ្រាវ និងការឆ្លើយតប ក្នុងការលុបបំបាត់ឱសថក្លែងក្លាយ និងអន់គុណភាព នៅក្នុងប្រទេសនិងទូទាំងតំបន់។ ការកសាង និងការថែរក្សាប្រព័ន្ធផ្គត់ផ្គង់ ដ៏មានប្រសិទ្ធភាពមួយ ដែលនឹងរួមចំណែកដល់ការធានាថាប្រជាជននៅក្នុងតំបន់ ជាពិសេសនៅតំបន់ដាច់ស្រយាលនៃបណ្តារដ្ឋសមាជិកអាស៊ាន អាចទទួលបានឱសថដែលមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ។ យើងទន្ទឹងរង់ចាំការផ្លាស់ប្តូរទស្សនៈ និងការសហការគ្នាបន្ថែមទៀត ក៏ដូចជាបន្តអនុវត្តនូវវិធានការដាក់ស្តែងលើឱសថក្លែងក្លាយ និងអន់គុណភាព នៅក្នុងបរិបទទូលំទូលាយនៃកិច្ចសហប្រតិបត្តិការសុខភាព នៅក្នុង និងនៅក្រៅអាស៊ាន។ យើងសូមប្តេជ្ញាបន្ថែមទៀតក្នុងការតស៊ូមតិ និងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាលើបញ្ហានេះ និងស្វែងរកការសហការបន្ថែមទៀត ក៏ដូចជាជំរុញរបៀបវារៈនៃការងារប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងអន់គុណភាព នៅក្នុងកិច្ចប្រជុំកំពូល អាស៊ី-អឺរ៉ុប លើកទី១៣ (13th ASEM) ដែលនឹងរៀបចំឡើងនៅឆ្នាំ ២០២០ នៅទីក្រុងភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។

៩. យើងបញ្ជាក់ជាថ្មីក្នុងការគាំទ្ររបស់យើងដើម្បីធានាសុវត្ថិភាពចំណីអាហារ ដោយសហប្រតិបត្តិការរួមគ្នានៅក្នុងតំបន់ ការទទួលស្គាល់លើសារៈសំខាន់នៃការវាយតម្លៃហានិភ័យ ដោយបង្កើតវិធានសុវត្ថិភាពចំណីអាហារផ្អែកលើភស្តុតាងជាមូលដ្ឋាន ដែលមានការសម្របសម្រួលដោយមជ្ឈមណ្ឌលវាយតម្លៃហានិភ័យអាស៊ាន (ARAC) សម្រាប់សុវត្ថិភាពចំណីអាហារ។

១០. យើងនៅតែប្តេជ្ញាពង្រឹងការថែទាំសុខភាពបឋម ដើម្បីសម្រេចឲ្យបាននូវការគ្របដណ្តប់សុខភាពជាសកល ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន និងធានាឱ្យមាន ការផ្គត់ផ្គង់ឱសថសារវន្តប្រើប្រាស់គ្រប់គ្រាន់និងទាន់ពេលវេលា និងអន្តរាគមន៍លើផ្នែកសុខភាពប្រកបដោយប្រសិទ្ធភាពនិងចំណាយឱ្យមានប្រសិទ្ធភាពនៅតាមមូលដ្ឋានព្យាបាល និងថែទាំសុខភាព និងការពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាល។

១១. យើងសូមកោតសរសើរចំពោះសមិទ្ធិផលរបស់ឧត្តមមន្ត្រីសុខាភិបាលអាស៊ានស្តីពីការអភិវឌ្ឍវិស័យសុខាភិបាល និង ក្រុមការងារសុខាភិបាលអាស៊ាន ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសុខភាព និងដំណើរការរបៀបវារៈអភិវឌ្ឍសុខភាពអាស៊ានក្រោយឆ្នាំ ២០១៥ ក្រោមការដឹកនាំប្រជុំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១៨ និង ២០១៩ ហើយនឹង បន្តដឹកនាំ ដោយប្រធានប្តូរវេននៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅឆ្នាំក្រោយនេះ ។

១២. យើងសូមប្រគល់ភារកិច្ចជូនមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីការអភិវឌ្ឍសុខភាពដូចខាងក្រោម៖

ក. ពិនិត្យចុងក្រោយលើផែនការសកម្មភាពអាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព តស៊ូមតិ និងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូ និងភាគីពាក់ព័ន្ធ រួមទាំងដៃគូនៅក្នុងកិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបលើកទី១៣ ដែលនឹងរៀបចំឡើងដោយព្រះរាជាណាចក្រកម្ពុជា។

ខ. ការគាំទ្រ ការតាមដាន និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីការងារបង្គោមសុខភាពអាស៊ាននៃរបៀបវារៈអភិវឌ្ឍន៍សុខភាពអាស៊ានក្រោយឆ្នាំ ២០១៥ និងវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការពហុវិស័យ និងពហុភាគីលើការអនុវត្តសេចក្តីប្រកាសទាក់ទងនឹងសុខភាព សមិទ្ធិផលនិងចំណុចខ្សោយ ដែលត្រូវផ្តល់ជាមគ្គុទេសន៍ឆ្ពោះទៅរកការពិនិត្យឡើងវិញជាបន្តបន្ទាប់ និងការអភិវឌ្ឍគម្រោងកម្មវិធីថ្មីសម្រាប់ឆ្នាំ ២០២១-២០២៥។

១៣. យើងទទួលស្គាល់ និងកោតសរសើរចំពោះការចូលរួមចំណែក និងការប្តេជ្ញាបផ្សេងៗទៀតដើម្បីសហការយ៉ាងជិតស្និទ្ធជាមួយដៃគូសន្ទនា និងអភិវឌ្ឍន៍ ដោយប្រកាន់ខ្ជាប់នូវបទដ្ឋាន ស្តីពីការចូលរួមរបស់អង្គភាពនានាជាមួយវិស័យសុខាភិបាលអាស៊ាន។

យើងកត់សំគាល់ពីការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍និងដៃគូសន្ទនា ដូច្នេះយើងបន្តប្តេជ្ញាចិត្ត សហការយ៉ាងជិតស្និទ្ធជាមួយដៃគូទាំងនោះ ដោយប្រកាន់ភ្ជាប់នូវ «វិធាននិងនិតិវិធីស្តីពីការចូលរួមរបស់អង្គភាពនានា ក្នុងវិស័យសុខាភិបាលអាស៊ាន» ។

យើងនឹងបន្តការផ្លាស់ប្តូរទស្សនៈ និងកិច្ចសហការក្នុងការអភិវឌ្ឍវិស័យសុខាភិបាល នៅឯកិច្ចប្រជុំបន្ទាប់នៅសាធារណៈរដ្ឋឥណ្ឌូនេស៊ី ក្នុងឆ្នាំ ២០២១ ។

FINAL

**JOINT STATEMENT**
**14th ASEAN HEALTH MINISTERS MEETING**
**29 AUGUST 2019, SIEM REAP, THE KINGDOM OF CAMBODIA**

**WE,** the Ministers of Health of ASEAN Member States (AMS), representing Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, convened the 14th ASEAN Health Ministers Meeting (AHMM) on 29 August 2019 in Siem Reap, the Kingdom of Cambodia.

**RECALLING** the ASEAN Leaders' vision of an ASEAN Community outlined in the 2015 Kuala Lumpur Declaration on the Establishment of the ASEAN Community and the simultaneous endorsement of "ASEAN 2025: Forging Ahead Together" containing among others, the ASEAN Socio-Cultural Community Blueprint 2025, at the 27th ASEAN Summit in November 2015 in Kuala Lumpur, Malaysia.

**REAFFIRMING** the commitment to the "2030 Agenda for Sustainable Development" as agreed by leaders at the 70th United Nations General Assembly in 2015 which includes an overarching health goal to "ensure healthy lives and promote well-being for all at all ages."

**ACKNOWLEDGING** the commitment to the goal of "Together Towards A Healthy ASEAN" at the 13th AHMM held on 6 September 2017 in Bandar Sari Begawan, Brunei Darussalam which commits to the multi-sectoral and multi-stakeholder planning and implementation of the ASEAN Leaders' Declarations on (1) Antimicrobial Resistance: Combating AMR through One Health Approach; (2) Ending All Forms of Malnutrition; and, (3) Disaster Health Management; and, to the implementation and monitoring of the four endorsed ASEAN Health Cluster Work Programmes and its twenty Health Priorities on Promoting Healthy Lifestyles; Responding to All Hazards and Emerging Threats; Strengthening Health Systems and Access to Care; and, Ensuring Food Safety.

**UNITED** by the mission to achieve the goals of the ASEAN Post-2015 Health Development Agenda, and to "Accelerate Health for All in ASEAN", including combating substandard and falsified medicines, ensuring sustainable health financing, strengthening capacity to implement International Health Regulations (IHR) through the Asia Pacific Strategy for Emerging Diseases and Public Health Emergencies (APSED III), and promoting innovations for enhancing quality of services, the 14th AHMM discussed and exchanged views on the preparation and response to future health challenges and upcoming health development agenda and priorities, and agreed as follows:

1. We agree to further sustain and utilise the gains from the implementation of the ASEAN Post-2015 Health Development Agenda and move forward to developing new work programmes and project initiatives for 2021 – 2025 based on the performance of work programmes for 2016 – 2020, and the whole-of-society and whole-of-government approaches.

2. We commit to promote healthy and active ageing through an enabling and supportive environment that facilitates strong and effective multi-sectoral cooperation through national and regional joint initiatives. We endorse the establishment of ASEAN Centre for Active Ageing and Innovation (ACAI) which would generate knowledge and innovation; support active ageing policies and their implementation; and, strengthen capacity and facilitate collaboration among AMS , international entities and other partners, on matters relevant to healthy and active ageing.

3. We reiterate our commitment to accelerate actions to prevent and control non-communicable diseases through increasing the capabilities of the communities and its people in promoting healthier lifestyles, mobilising sustainable funds for NCD and strengthening the multi-sectoral and multi-stakeholder engagements on implementing the WHO recommended "best buy" and other interventions in line with country context, addressing commercial and social determinants of NCD; and the ASEAN Strategic Framework and Action Plan for Nutrition 2018 - 2030 to promote good nutrition and healthy diet; promoting physical and mental health activities; NCD early diagnosis and treatment programmes; and, prevention of injuries.

4. We further reiterate our commitment to the effective cooperation and implementation of ongoing activities for the preparedness, prevention, detection and response to communicable, emerging and re-emerging diseases including pandemics and neglected tropical diseases, and other public health emergencies or health impacts of disasters, and health security threats.

5. We support the One ASEAN One Response in disaster management and humanitarian assistance by operationalising the Plan of Action to Implement the ASEAN Leaders' Declaration on Disaster Health Management. We acknowledge the ongoing partnerships on Strengthening ASEAN Regional Capacity on Disaster Health Management; and Programme on Mitigation of Biological Threats.

6. We reaffirm our commitment to the ASEAN Leaders' Declaration on Antimicrobial Resistance (AMR), and look forward to the finalisation of the ASEAN Strategic Framework on Combating AMR through One Health Approach (2019-2030) to contribute in achieving relevant national, regional, and global health security, and relevant sustainable development goals and targets, for the human, animal and agriculture, environmental health, and food safety.

7. We further reaffirm our commitment to combat substandard and falsified medical products.

8. We support the finalisation of the ASEAN Action Plan developed with the World Health Organization (WHO) in combating substandard and falsified medicines by strengthening national regulatory mechanisms; coordination and collaboration on the sustained implementation on the prevention, detection and response to eliminate substandard and falsified medicines within countries and across the region, among others; and, building and maintaining an efficient robust supply system which will contribute to ensuring that populations within the region especially in remote areas of AMS have access to safe, effective, affordable and quality medicines. We look forward to further exchanges of views and collaboration, as well as pursue and implement concrete actions on substandard and falsified medicines in the wider context of health cooperation within and outside ASEAN. We further commit to advocate and closely collaborate with relevant partners and stakeholders on this matter as well as to drive the agenda, and seek further collaboration on substandard and falsified medicines at the 13th Asia-Europe Summit (13th ASEM) to be held in 2020 in Phnom Penh, The Kingdom of Cambodia.

9. We reaffirm our support to ensure food safety by working together in the region, recognising the importance of risk assessment in developing evidence-based food safety measures, which are facilitated by the ASEAN Risk Assessment Centre (ARAC) for Food Safety.

10. We remain committed to strengthen primary health care in order to achieve Universal Health Coverage among AMS , and ensure the availability and timely provision of essential medicines and cost-effective health interventions at healthcare facilities and building-up the capacity of health workers.

11. We appreciate the achievements made by the ASEAN Senior Officials on Health Development and the ASEAN Health Clusters in strengthening health cooperation and operationalising the ASEAN Post-2015 Health Development Agenda under the Chairpersonship of the Ministry of Health of the Kingdom of Cambodia in 2018 and 2019, and look forward to the incoming Chairpersonship of the Republic of Indonesia.

12. We task the ASEAN Senior Officials on Health Development on the following:

   a. Finalise the ASEAN Action Plan to address substandard and falsified medicines, to advocate and closely collaborate with relevant partners and stakeholders including partners in the 13th Asia-Europe Summit 2020 to be hosted by the Kingdom of Cambodia.

   b. Support the effective monitoring and evaluation of the performance of ASEAN Health Cluster Work Programmes of the ASEAN Post 2015 Health Development Agenda, and progress of multi-sectoral and multi-stakeholder cooperation on the implementation of health-related Declarations, their achievement and weaknesses, which shall provide as a guidance towards the subsequent review and development of the new set of programme for 2021-2025.

13. We recognise and appreciate the contribution by, and further commit to collaborate closely with Dialogue and Development Partners with adherence to the *Rules of Procedure on the Engagement of Entities with the ASEAN Health Sector.*

We look forward to further exchange of views and collaboration on health development at our next Meeting in the Republic of Indonesia in 2021.

********